**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងព្រះសីហនុ**

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ២៣៤ ចុះថ្ងៃទី ២៣

ខែ តុលា ឆ្នាំ ២០០៤

<u>សាលក្រម</u>

លេខ ០៥ ចុះថ្ងៃទី ២៥

ខែ មករា ឆ្នាំ ២០០៥

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅ តុលាការក្រុងព្រះសីហនុ នាថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅនេះ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

**<u>មេធាវី</u>**

លោកស្រី [redacted] ជា

លោក [redacted] **សោភា** (អវត្តមាន)

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥
**ក្រឡាបញ្ជី**
[redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៤ ដែលមានជន ជាប់ចោទឈ្មោះ :

-ឈ្មោះ **ខ ជ រ** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរចំណាសង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ទីលំនៅសព្វថ្ងៃ ភូមិអូរចំណា សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ី ធ្វើស្រែ កំរិតវប្បធម៌អត់បានរៀន ឪពុកឈ្មោះ **ម គ រ** (ស) ម្តាយឈ្មោះ **ស ឡ** (ស) នៅលីវ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៤ ។

-ជាប់ចោទពីបទ<u>**ឃាតកម្មគិតទុកជាមុន**</u> ប្រព្រឹត្តនៅភូមិត្រពាំងមូល សង្កាត់ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង អោយផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ឈ្មោះ **គ ឈ** ភេទប្រុស អាយុ ៦៨ឆ្នាំ មុខរបររកស៊ី ធ្វើស្រែ ទីលំនៅក្រុម ៦ ភូមិត្រពាំងមូល សង្កាត់ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ សព្វថ្ងៃស្លាប់ ។

-ឈ្មោះ **ន គន** ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាល ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មានទីលំនៅសព្វថ្ងៃក្រុម ៦ ភូមិត្រពាំងមូល សង្កាត់ជើង

ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១១ ដសព.០៥ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៥ របស់ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៣៩ ត.ព.០៥ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៥ របស់ចៅក្រមស៊ើបអង្កេតបន្ទប់ទី III នៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៦០ តព.០៥ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

-កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ឈ្មោះ **ទ ជ រ** និង បក្ខពួកចំនួន ០៣នាក់ទៀតបាននាំយកឈ្មោះ **គ យ** ទៅសំលាប់ក្នុងព្រៃ ដោយអោយឈ្មោះ **ទ ជ រ** ជាអ្នកមើលផ្លូវ ក្រោយពីសំលាប់ហើយ បក្ខពួក **ទ ជ រ** ក៏បើកឡានគេចខ្លួនអស់ទៅ នៅតែ **ទ ជ រ** នៅរង់ចាំមើលផ្លូវតែគេនៅក្បែរសាកសពដែរនោះ ក៏ត្រូវបងប្អូនក្រុមគ្រួសារសពឃាត់ខ្លួន **ទ ជ រ** រួចបញ្ជូនមកសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធី ។ ឯសពរបស់ឈ្មោះ **គ យ** ត្រូវបានបងប្អូនយកទៅធ្វើបុណ្យតាមប្រពៃណី ។

## នាពេលសវនាការ

-ឈ្មោះ **ទ ជ រ** ជាជនជាប់ចោទបានឆ្លើយថា នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ខ្លួន និង បក្ខពួកខ្លួនបានជួបជុំគ្នានៅបេនឡានផ្សារលើ ក្រុងព្រះសីហនុ ហើយបានពិភាក្សាគ្នា ក្នុងការសំលាប់មនុស្ស នៅសង្កាត់ជើងគោ ដើម្បីបានប្រាក់ចែកគ្នាចាយ ក្នុងនោះគឺឈ្មោះ **ឃ ខ** ជាមេ. ឈ្មោះ **ក ឧ** ជាមេរង ខ្លួន និងឈ្មោះ **អ ឈ** និងឈ្មោះ **ឃ ទ** ជាកូនចៅ មេ និង កូនចៅសុទ្ធតែធ្លាប់ប្រើប្រាស់គ្រឿងញៀន ឯខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ ។ មុននឹងសំលាប់មនុស្សពួកគាត់បានសន្យាថា អោយប្រាក់មកខ្លួនចំនួន ០១លានរៀល ខ្លួនចង់បានប្រាក់ ដើម្បីព្យាបាលជំងឺឱ្យអ៊ំរបស់ខ្លួន ហើយខ្លួនក៏ធ្វើដំណើរទៅ ពេលដល់ផ្សារវាលរេញក៏ជួបបក្ខពួកខ្លួន គេក៏អោយដបទឹកសុទ្ធខ្មែរមួយមកអោយខ្លួន នៅក្នុងដបនោះមានទឹកល្អក់ពណ៌ថ្លា ហើយគាត់ថាមានថ្នាំពុលក្នុងដបទឹកសុទ្ធនោះ ព្រមទាំងហាមខ្លួនមិនអោយផឹកទៀតផង គេប្រាប់ថាអោយខ្លួនទៅជួបជុំគ្នានៅជើងគោ ខ្លួនក៏មកតាមការប្រាប់របស់ពួកខ្លួននោះទៅ ពេលទៅដល់លូទឹកក្នុងសង្កាត់ជើងគោ ក៏ឃើញឈ្មោះ **គ យ** គាត់អង្គុយនៅមាត់លូទឹក ខ្លួនក៏ទៅអង្គុយក្បែរនោះដែរ ខ្លួនក៏បោះដបទឹកសុទ្ធនោះចោលទៅក្នុងព្រៃ បន្ទាប់មកក៏ឃើញបក្ខពួកខ្លួន ហើយក៏នាំឈ្មោះ **គ យ** ចូលទៅក្នុងព្រៃ ហើយគេប្រាប់ខ្លួនថា អោយខ្លួនជាអ្នកយាមផ្លូវ បើមាននរណា ឬ បងប្អូនក្រុមគ្រួសារជនរងគ្រោះមកអោយរត់ទៅប្រាប់គេ ខ្លួនក៏ធ្វើតាមបញ្ជារបស់គេទាំងអស់ ពេលសំលាប់យ៉ាងម៉េចខ្លួនមិនបានឃើញទេ ព្រោះខ្លួននៅឆ្ងាយការសំលាប់នេះប្រើពេលវេលាអស់កន្លះម៉ោង ហើយមិនឃើញគេត្រឡប់មកវិញសោះ ខ្លួននៅរង់ចាំគេរហូតដល់ក្រុមគ្រួសារគេសង្ស័យគេក៏ឃាត់ខ្លួនតែម្តង ខ្លួនសុំបញ្ជាក់ទៀតថា ខ្លួនឃើញឈ្មោះ **គ យ** ពាក់អាវសខោខ្មៅជើងវែង ពេលពួកខ្លួនយកគាត់សំលាប់នោះនៅចំងាយពីខ្លួនប្រហែល ១០០ម៉ែត្របុណ្ណោះ ក្នុងពេលគេកំពុងសំលាប់នោះគ្មានឮសូរសំរែកពីជនរងគ្រោះឡើយ ។

ម្យ៉ាងទៀតចំពោះ **គ ឧ** គឺខ្លួនមិនស្គាល់ឡើយ ហើយមិនមែនជាបក្ខពួករបស់ខ្លួនដែរ ក្នុងការសំលាប់ឈ្មោះ **គ យ** នោះឡើយ ។

-ឈ្មោះ គ គ ឆ ជាដើមបណ្តឹងបានឆ្លើយថា ខ្លួនត្រូវជាកូនរបស់ជនរងគ្រោះ នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ១២ថ្ងៃត្រង់ ខ្លួនកំពុងតែហូបបាយ ស្រាប់បងខ្លួនបានប្រាប់ថា បាត់ឪពុកហើយពុំឃើញគាត់មកហូបបាយថ្ងៃត្រង់ទេ ក្រោយពេលដែលគាត់យកក្របីអោយស៊ីស្មៅ ។ ឮដំណឹងថា បាត់ឪពុកយ៉ាងដូច្នេះខ្លួន ក៏បបួលក្រុមគ្រួសារទាំងអស់គ្នាដើររកទាំងយប់ទាំងថ្ងៃ គឺដើររក ០៣ថ្ងៃ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ១:៣០នាទី ក៏ឃើញឪពុកខ្លួនដេកស្លាប់ក្នុងវាលស្រែក្នុងថ្លុកក្របីដែលជាកន្លែងដែលគាត់ឧស្សាហ៍ឃ្វាលក្របីនៅទីនោះ មានមែកឈើគ្របពីលើសាកសពថែមទៀតផង សាកសពឪពុកខ្លួនគាត់ពាក់អាវស ខោខ្មៅ ដូចដែលជនល្មើសបានឆ្លើយអញ្ចឹងមែន ។ ពេលខ្លួនឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេតថា ប្រហែលមិនមែន ច ជ រ សំលាប់ឪពុកខ្លួនទេ ព្រោះគ្មានភស្តុតាង និង សាក្សីណាបញ្ជាក់បានឃើញទាល់តែសោះ ឮតែពីប្រជាជនឈ្មោះ ផានី បានប្រាប់ក្រុមគ្រួសារខ្លួនថា ឈ្មោះ គ ឆ ត្រូវខ្មោចចូលហើយរត់ចូលទៅក្នុងព្រៃ ដល់ពេលត្រឡប់មកវិញ គ ឆ គេអះអាងថា គេជាអ្នកកាប់ឪពុកខ្លួន ដូច្នេះខ្លួនក៏សន្និដ្ឋានថា គ ឆ ទៅ តែដល់ពេលសវនាការនោះ ជនជាប់ចោទឈ្មោះ ច ជ រ វាឆ្លើយច្បាស់យ៉ាងដូច្នេះហើយ គឺបក្ខពួកវាជាអ្នកសំលាប់ឪពុកខ្លួន ហេតុនេះទើបឃើញមុខមាត់ពិតរបស់ជនជាប់ចោទក្នុងរឿងនេះខ្លួនសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ឯសំណងជំងឺចិត្តខ្លួនពុំទាមទារអ្វីទេ ។

-ជ ឆ ជាសាក្សីបានឆ្លើយថា កាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤ ខ្លួនបានដឹងថាឈ្មោះ គ ឆ ត្រូវខ្មោចចូល ហើយរត់ចូលព្រៃអស់ចំនួន ០២យប់ ០២ថ្ងៃ ដល់ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ ប្រហែលជាម៉ោង ០៩ព្រឹកទើបឈ្មោះ គ ឆ មកផ្ទះវិញ ខ្លួនក៏បានសួរ គ ឆ ។ ក៏ប្រាប់ខ្លួនថា វាជាអ្នកកាប់ តាឃួន ហើយកាយដីកប់មុខជិតថែមទៀត ព្រមទាំងប្រាប់ថា វាបានកាប់មែកព្រីងគ្របពីលើថែមទៀតផង ខ្លួនក៏បានមកប្រាប់ឈ្មោះ ឆឹន និងក្រុមគ្រួសារសពអោយដឹងពីបញ្ហានេះ ក៏នាំទៅរកក៏ឃើញសាកសពដូចសំដីដែល គ ឆ និយាយប្រាប់ខ្លួនអញ្ចឹងដែរ ។ ឯរឿងរ៉ាវអ្វីផ្សេងទៀតខ្លួនមិនបានដឹងឡើយ ។

-ឈ្មោះ ស គ ជាសាក្សីបានឆ្លើយថា ឈ្មោះ គ ឆ ដែលខ្មោចចូលហើយរត់ចូលក្នុងព្រៃ ពេលត្រឡប់មកវិញ ស្រាប់តែឮ គ ឆ វានិយាយប្រាប់ ផានី និង ខ្លួន ថាវាបានសំលាប់ តាឃួន និង យកដីកប់មុខ និង កាប់មែកព្រីងគ្របពីលើថែមទៀត ហើយ តាឃួន ត្រូវបានស្លាប់ ហើយក្រុមគ្រួសារធ្វើបុណ្យតាមប្រពៃណី ឯរឿងរ៉ាវអ្វីផ្សេងទៀត ខ្លួនមិនបានដឹងឡើយ ។

-ឈ្មោះ គ ឆ ជាសាក្សីបានឆ្លើយថា កន្លងមកខ្លួនស្គាល់ តាឃួន ជាមនុស្សរស់នៅក្នុងភូមិជាមួយគ្នា ហើយអ្នកណាសំលាប់ឈ្មោះ តាឃួន នោះ ខ្លួនពុំបានដឹងឡើយ នៅថ្ងៃទី ២០-២១-២២ និងថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៤ ខ្លួនពុំបានទៅណាទេ គឺនៅផ្ទះទាំងយប់ទាំងថ្ងៃ ព្រោះខ្លួនដេកព្យាបាលជំងឺគ្រុនចាញ់ ហើយសព្វថ្ងៃមិនទាន់ជាសះស្បើយនៅឡើយ ហើយកន្លងមកខ្លួនមានត្រូវអំបែងគ្រាប់បែក គឺត្រូវដៃ និង ត្រូវក្បាលអំបែងគ្រាប់នៅដៃយកចេញហើយ ឯនៅក្បាលមិនបានយកចេញទេ ខ្លួនព្យាបាលអស់ប្រាក់ជាច្រើន ក្នុងរឿងនេះខ្លួនគ្មានបានសំលាប់ឈ្មោះ គ ឃ នោះឡើយ ។

-តាមការអានចម្លើយឈ្មោះ ស ឡ ជាសាក្សីឆ្លើយថា នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ពេលខ្លួនប្រចាំការនៅវេលាម៉ោង ១៨:៣០នាទី ស្រាប់តែឃើញឈ្មោះ ភ អ ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ជើងគោ បាននាំខ្លួនជនល្មើស ច ជ រ មកដល់កន្លែងអធិការដ្ឋាននគរបាលខណ្ឌព្រែកព្នៅ លោក ភ អ បានប្រាប់ខ្លួនថា ពេលប្រជាពលរដ្ឋដើររកសាកសពក៏ឃើញឈ្មោះ ច ជ រ ដើរចេញពីក្នុងព្រៃដែលនៅកន្លែងក្បែរសាកសព ខ្លួនក៏បានសួរចម្លើយ ច ជរ។ បានប្រាប់ថា មុនពេលកើតហេតុបក្ខពួកគេបានដាក់ថ្នាំពុលក្នុងទឹកសុទ្ធ ហើយហាមកុំអោយនរណាផឹកចាំស្អែកឡើងចាំ

ជួបគ្នានៅសង្កាត់ជើងគោ ។ ខ្លួនក៏បង្កសំណុំរឿង និង បញ្ជូនខ្លួនជនល្មើសមកស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ ដើម្បីចាត់ការតាមនីតិវិធី ។

-ឈ្មោះ **ភ អ** ជាសាក្សីបានឆ្លើយថា នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ០៥ល្ងាចឈ្មោះ **នីន** បានមកប្រាប់ខ្លួនថា ឪពុករបស់គាត់ឈ្មោះ **គ ឃ** បានបាត់ខ្លួនមិនដឹងទៅណាទេ ឮដូច្នេះខ្លួនក៏បាននាំកំលាំងចុះទៅស្រាវជ្រាវនៅចំណុចដែល **គ ឃ** ទៅឃ្វាលក្របី និង ទៅដល់ផ្ទះរបស់ឈ្មោះ **នីន** ឃើញក្រុមគ្រួសាររបស់ **នីន** បានឃាត់ខ្លួនក្មេងម្នាក់ឈ្មោះ **ច ជ រ** ព្រមទាំងនាំខ្លួន **ច ជ រ** មកអោយខ្លួនទៀតផង គឺនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ហើយប្រាប់ថា ឈ្មោះនេះបានអង្គុយលើថ្មជិតកង់របស់ឪពុក **នីន** ខ្លួនក៏ឃាត់ខ្លួន និង បញ្ជូនមកអធិការដ្ឋាននគរបាលខណ្ឌព្រៃនប់ ដើម្បីចាត់ការតាមច្បាប់ ។ តែជនល្មើសបានប្រាប់ខ្លួនថា វាអោយទឹកដែលមានថ្នាំពុលនៅក្នុងដបអោយឈ្មោះ **គ ឃ** ផឹក ខ្លួនក៏បានចូលរួមពិនិត្យសាកសព ហើយសពនេះគេកាយដី និង ភក់គ្របពីលើការកប់នេះ ប្រើដោយដៃកាយដីកប់តែប៉ុណ្ណោះ មិនមានប្រើចបអ្វីទេ ឯដបទឹកសុទ្ធខ្លួនដើររកដែរតែរកមិនឃើញ ។

-បានឃើញកំណត់ហេតុពិនិត្យសាកសពចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៤ របស់ការិយាល័យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ បានពិនិត្យសាកសពឈ្មោះ **គ ឃ** ភេទប្រុស អាយុ ៦៨ឆ្នាំ ក្នុងថ្លុកទឹកដេកផ្ងា មានដីលប់ពីលើមួយកំណាត់ខ្លួន និង មានមែកព្រីងសង្កត់ពីលើ ស្លាកស្នាមរបួសពីខាងក្រោយកញ្ចឹងកដៃសាកសពមួយកន្លែងប្រវែងបណ្តោយម្ភៃសង់ទីម៉ែត្រប្រាំបី និង ទទឹងប្រវែង បីសង់ទីម៉ែត្រ. របួសលើត្រចៀកខាងស្តាំប្រវែងប្រាំពីរសង់ទី ម៉ែត្រ និង ទទឹងប្រវែងពីរសង់ទីម៉ែត្រ ។ តាមការសន្និដ្ឋានរបស់សមត្ថកិច្ច គឺរបួសចំនួន ០២កន្លែង ដោយត្រូវជនល្មើសវាយនិង វត្ថុរឹង ស្លាប់នៅនឹងកន្លែងកើតហេតុ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ច ជ រ** ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិត្រពាំងមូល សង្កាត់ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ហេតុនេះសុំអោយតុលាការវិនិច្ឆ័យទោសតាមច្បាប់ដោយអនុគ្រោះ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនជាអនីតិជន ឪពុកម្តាយស្លាប់ចោលអស់ គ្មាននរណាជួយចិញ្ចឹម ល្ងង់ខ្លៅមានស្មារតីមិនសូវល្អករិតវប្បធម៌មិនចេះអក្សរទៀតដែរ ។ តាមសំដីសារភាពរបស់កូនក្តីខ្លួនក្នុងពេលសវនាការនេះមិនអាចយកជាការបានទេ ព្រោះកូនក្តីខ្លួនម្តងនិយាយថាអញ្ចេះ ម្តងទៀតថាអញ្ចុះ ម្តងបានធ្វើ ម្តងទៀតថា មិនបានសំលាប់ទេ ។ ពេលជនរងគ្រោះបានស្លាប់កូនក្តីខ្លួនបានជួយដើររកជនរងគ្រោះជាមួយក្រុមគ្រួសារជនរងគ្រោះផងដែរ ។ តាមសំដីរបស់ដើមបណ្តឹងគាត់បានសន្និដ្ឋានថា កូនក្តីខ្លួនមិនបានសំលាប់ឪពុកគាត់ទេ អ្នកសំលាប់ គឺអ្នកផ្សេងទៅវិញ សូម្បីតែសាក្សីឈ្មោះ **ដារី** និង ឈ្មោះ **ស គ** គឺគាត់បានស្តាប់ចម្លើយរបស់ឈ្មោះ **គ ឧ** ដោយផ្ទាល់ ហើយឈ្មោះ **គ ឧ** បានបញ្ជាក់ថា ខ្លួនគេជាអ្នកសំលាប់ **គ ឃ** ទៀតផង ។ ចំណុចមួយទៀត តាមរយៈការស៊ើបអង្កេតឃើញថា គ្មានភស្តុតាង ឬ សាក្សីណាមួយដាក់បន្ទុកកូនក្តីខ្លួនឡើយ គឺឯកសារសំណុំរឿងមិនមានភាពច្បាស់លាស់ បើផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ និង មាត្រា ៤៨ ក្នុងរដ្ឋធម្មនុញ្ញក៏បានចែងពីសិទ្ធិកុមារផងដែរ ។ ដោយផ្អែកលើកត្តាខាងលើនេះ សូមអោយតុលាការដោះលែងកូនក្តីខ្លួនអោយមានសិទ្ធិសេរីភាព បានទៅចូលរួមកសាងសង្គមនិងគេផង ដោយអនុគ្រោះ ។

-ឈ្មោះ **ច ជ រ** ជាជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់របស់ខ្លួនថា សុំអោយតុលាការដោះលែងខ្លួនអោយមានសិទ្ធិសេរីភាពផង ដោយអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយ និង ការអានចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្ដាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ពិតជាមានអំពើសំលាប់មនុស្ស ដែលបណ្ដាលអោយឈ្មោះ គ ឃ រងគ្រោះរហូតដល់បាត់បង់ជីវិត នៅត្រង់ចំណុចក្បាលអូរជើងគោ ក្នុងព្រៃបុស ក្រុម ៩ ភូមិត្រពាំងមូល សង្កាត់ជើងគោ ប្រាកដមែន ។

-ក្រោយពីមរណភាពរបស់ គ ឃ រួចមក សមត្ថកិច្ចមូលដ្ឋានបានស្រាវជ្រាវរកជនដែលបានប្រព្រឹត្តបទល្មើស ហើយបានធ្វើការឃាត់ខ្លួនឈ្មោះ ច ជ រ ដែលជាជនសង្ស័យ នៅកន្លែងកើតហេតុ ។

-តាមចម្លើយរបស់ ច ជ រ នៅនគរបាលយុត្តិធម៌ អយ្យការ និង នៅក្នុងអង្គសវនាការនេះបានសារភាពថា ខ្លួន និង បក្ខពួកមានឈ្មោះ អ ឈ, ឈ្មោះ ង ច និង ឈ្មោះ ង ខ បានរៀបចំគំរោងសំលាប់ គ ឃ ប្រាកដមែន ។ ក្នុងការសំលាប់ខ្លួន (ច ជ រ) ជាអ្នកយាមផ្លូវ ហើយបក្ខពួកខ្លួនជាអ្នកសំលាប់ផ្ទាល់ ។

-ការដែល ច ជ រ ចូលរួមធ្វើសកម្មភាពយាមផ្លូវនោះ ដោយសារបក្ខពួករបស់គេសន្យាអោយប្រាក់ ០១លានរៀល ។

-ឈ្មោះ ច ជ រ និង បក្ខពួកបានរៀបចំគំរោងផែនការជាមុន ដោយពិនិត្យមើលពេលវេលា ទីកន្លែងភូមិសាស្ត្រ ក្នុងការសំលាប់មនុស្ស (គ ឃ) ។

-ឈ្មោះ ច ជ រ និង បក្ខពួកបានប្រើប្រាស់ និង ចែកចាយគ្រឿងញៀន ហើយបានរៀបចំជាក្រុមបងធំបងតូចតាមលំដាប់លំដោយ ដូចជា បងធំទី ១ ឈ្មោះ ង ខ និងបងធំទី ២ ឈ្មោះ អ ឌ ។

-តាមកំណត់ហេតុពិនិត្យសាកសពរបស់នគរបាលបច្ចេកទេសវិទ្យាសាស្ត្រ បានបញ្ជាក់ថា : សាកសពមានរបួសពីរកន្លែង ដោយត្រូវជនល្មើសវាយនឹងវត្ថុរឹងស្លាប់នៅនឹងកន្លែងកើតហេតុ ។

-មានភស្តុតាងស៊ីចង្វាក់គ្នា ដែលអាចបញ្ជាក់បានថា ឈ្មោះ ច ជ រ និង បក្ខពួក ពិតជាបានសំលាប់ឈ្មោះ គ ឃ គិតទុកជាមុន កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ប្រាកដមែន ។ បទល្មើសនេះមានចែង និង ផ្ដន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនជាប់ចោទឈ្មោះ ង ខ, ង ច, ឈ្មោះ អ ឈ គ្មានសាវតាជាតិត្រូវបានព្រះរាជអាជ្ញាបង្អង់បណ្ដឹងអាជ្ញារួចហើយ ។

-អំពើរបស់ ច ជ រ ដែលបានរួមគ្នាសំលាប់ឈ្មោះ គ ឃ នេះ បានស្ដែងចេញយ៉ាងសកម្ម បង្កអោយមានអន្តរាយដល់សន្តិសុខសង្គមយ៉ាងធ្ងន់ធ្ងរ ។

-ដើមបណ្តឹងរដ្ឋប្បវេណីសុំអោយតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ចំណែកសំណងរដ្ឋប្បវេណីមិនទាមទារទេ ។

-ឈ្មោះ **ទ ជ រ** ជាអនីតិជន មិនចេះអក្សរជាកូនកំព្រា ការប្រព្រឹត្តនេះដោយខ្លួនត្រូវការប្រាក់ដើម្បីព្យាបាលអ៊ុំដែលមានជំងឺ ការប្រព្រឹត្តបទល្មើសជាលើកដំបូងដែលស្ថានភាពនេះអាចអោយតុលាការយកមកពិចារណាលើស្ថានសំរាលទោសតាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលក្នុងការវិនិច្ឆ័យសេចក្តីបាន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ទ ជ រ** ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅត្រង់ចំណុចក្បាលអូរជើងគោ ក្នុងព្រៃបុស ក្រុម ៩ ភូមិត្រពាំងមូល សង្កាត់ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

## <u>សំ រេ ច</u> :

<u>**ផ្តន្ទាទោស**</u> :

១-ផ្តន្ទាទោសឈ្មោះ **ទ ជ រ** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ កើតនៅភូមិអូរចំណា សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មានទីលំនៅសព្វថ្ងៃក្រុម២ ភូមិអូរចំណា សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ នៅលីវ ឪពុកឈ្មោះ **ម គ រ** (ស) ម្តាយឈ្មោះ **ស ឡ** (ស) ទោសពីមុនគ្មាន ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ ០៦ខែ ( ប្រាំពីរឆ្នាំ ប្រាំមួយខែ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ពីប<u>ទឃាតកម្មគិតទុកជាមុ</u>ន ប្រព្រឹត្តនៅត្រង់ចំណុចក្បាលអូរជើងគោ ក្នុងព្រៃបុស ក្រុម៩ ភូមិត្រពាំងមូល សង្កាត់ជើងគោ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមា<u>នចែងអោយផ្តន្ទាទោសតាមមាត្រា</u> ៣ នៃ<u>ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល</u> ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ **ទ ជ រ** និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជំរះ** |
| [redacted] | [redacted] |